ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពត៌មាន

០០៣៧/៩៩ ព.ម.សរ.ព

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩

# សារាចរណែនាំ

រយៈកាលកន្លងមក គ្រប់ស្ថានីយ៍វិទ្យុទូរទស្សន៍ និងទូរទស្សន៍ខ្សែកាបបានខិតខំអនុវត្តតាមការណែនាំជាបន្តបន្ទាប់របស់ក្រសួងពត៌មាន ពិសេសអនុវត្តតាមបទបញ្ជាណែនាំស្តីពីវិស័យសោតទស្សន៍ ដោយទទួលនូវលទ្ធផលល្អប្រសើរ ហើយមានស្មារតីទទួលខុសត្រូវជាប្រចាំនូវរាល់កម្មវិធី និងពេលម៉ោងផ្សាយ ។

ទន្ទឹមនេះដែរ ក្រសួងពត៌មានសង្កេតឃើញ នៅមានចំណុចអសកម្មសេសសល់ខ្លះៗ ដែលពុំទាន់អនុវត្តបាននៅឡើយ ។ ដូច្នេះ ដើម្បីអោយសមស្របទៅនឹង ការយកចិត្តទុកដាក់នៃសង្គម ការគោរពសិទ្ធមនុស្ស ការគោរពច្បាប់ និងសេរីភាពនៃការបញ្ចេញមតិ អោយកាន់តែសុក្រិត្យថែមទៀតនោះ ក្រសួងពត៌មានសូមធ្វើការណែនាំលើវិស័យការងារផ្សព្វផ្សាយដូចតទៅៈ

១-ស្ថានីយ៍វិទ្យុទាំងអស់ ត្រូវចាក់បទភ្លេងគោរពទង់ជាតិ ដោយបន្តផ្ទាល់ពីស្ថានីយ៍វិទ្យុជាតិអោយបានព្រមៗគ្នា នៅវេលាម៉ោង៧.០០ព្រឹក និងនៅវេលាម៉ោង១៧.០០ល្ងាច ដោយបន្ទឹពាក្យ "សូមគោរពទង់ជាតិ" ។ ចំពោះស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវចាក់បទភ្លេងគោរពទង់ជាតិ និងរូបភាពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាបក់រវិចៗ ដោយបន្តផ្ទាល់ពីស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា អោយបានព្រមៗគ្នានៅវេលាម៉ោង ១៧.០០ ល្ងាច ។

២- ស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវផ្សាយពត៌មានអោយឯកភាពគ្នា នៅវេលាម៉ោង១៩.០០ល្ងាច ហើយប្រភពពត៌មានទាំងអស់ត្រូវឈរលើមូលដ្ឋាននៃការពិត មិនលំអៀង មិនរំលោភលើសេរីភាពរបស់បុគ្គលណាមួយឡើយ ។

រាល់ការផ្សព្វផ្សាយមិនអនុញ្ញាតអោយបកស្រាយ មិនត្រូវប៉ះពាល់ព្រះមហាក្សត្រ គោលនយោបាយរាជរដ្ឋាភិបាល សន្តិសុខសណ្តាប់ធ្នាប់សង្គម និងវប្បធម៌ប្រពៃណីខ្មែរ និងមិនផ្សាយអោយមានការប្រកាន់ពូជសាសន៍ និងប្រឆាំងជំនឿសាសនា ។មិនអនុញ្ញាតអោយផ្សាយពាណិជ្ជកម្ម ក្នុងចន្លោះម៉ោង ផ្សាយពត៌មានជាតិ និងអន្តរជាតិ ។

៣- ស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវចាក់បញ្ចាំងភាពយន្តវីដេអូខ្មែរ ក្រោយពេលផ្សាយពត៌មានវេលាម៉ោង១៩.០០ចប់ អោយបាន៣ថ្ងៃក្នុងមួយសប្តាហ៍ ។ចំណែក៤ថ្ងៃទៀត ត្រូវបង្កើតកម្មវិធីសិល្បៈ នាទីល្បែងកំសាន្តផ្សេងៗ ដើម្បីលើកស្ទួយវិស័យសិល្បៈវប្បធម៌ខ្មែរ ។

៤- ស្ថានីយ៍ទូរទស្សន៍-ទូរទស្សន៍ខ្សែកាបទាំងអស់ មិនអនុញ្ញាតអោយបញ្ចាំងដាច់ខាត នូវឈុតរំលោភ និងអាសអាភាស ដែលមាននៅក្នុងសាច់រឿងភាពយន្តវីដេអូ ។

៥- ស្ថានីយ៍ទូរទស្សន៍-ទូរទស្សន៍ខ្សែកាបទាំងអស់ ក្នុងកម្មវិធីខារ៉ាអូខេ នាទីសំដែងសិល្បៈ និងកម្មវិធីកំសាន្តផ្សេងៗទៀត ត្រូវជ្រើសរើស និងស្លៀកពាក់អោយបានសមរម្យ មានលក្ខណៈជានារីខ្មែរ កុំអោយលេចលើខើចក្រោមពេក មានចរិតស៊ិចស៊ីហួសហេតុ ដែលជះឥទ្ធិពលអាក្រក់ដល់សេចក្តីថ្លៃថ្នូរ ។ហើយត្រូវប្រើពាក្យពេជន៍អោយបានត្រឹមត្រូវ តាមអក្ខរាវិរុទ្ធ និងអក្សរសាស្ត្រជាតិយើង។

៦- ស្ថានីយ៍ទូរទស្សន៍-ទូរទស្សន៍ខ្សែកាបទាំងអស់ ត្រូវកាត់បន្ថយការបញ្ចាំងភាពយន្តវីដេអូ ដែលមានសាច់រឿងកាប់ចាក់ បងធំ ការចាប់ជម្រិតមនុស្ស ការបាញ់ប្រហារ ភេរវកម្ម ដែលមានសកម្មភាពសាហាវឃោរឃៅ អោយបានជាអប្បបរមា ហើយអាចបញ្ចាំងពីម៉ោង២១.០០ឡើងទៅ ។

៧- ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ មិនត្រូវពណ៌នា ឬចាក់បញ្ចាំងពីសកម្មភាពឃោរឃៅ ធ្វើអោយមានការភ័យខ្លាចដល់កុមារ ។ហើយមិនត្រូវអោយកុមារ ទៅចូលរួមសំដែងក្នុងកម្មវិធីគ្មានការអប់រំ ដែលជះឥទ្ធិពលអាក្រក់ដល់កុមារទូទៅ ។

៨- ស្ថានីយ៍វិទ្យុទាំងអស់ ត្រូវកាត់បន្ថយអោយបានជាអតិបរមា នូវរាល់កម្មវិធីសំណេះសំណាលតាមទូរស័ព្ទ នាទីសំណូមពរបទចំរៀង ដែលមានពាក្យសំដីផ្តេះផ្តងលេបខាយ ពុំសមរម្យ ធ្វើអោយប៉ះពាល់អ្នកស្តាប់ គ្រប់ស្រទាប់មហាជន ហើយត្រូវប្រើពាក្យពេជន៍អោយមានភាពថ្លៃថ្នូរ ជៀសវាងការប្រើពាក្យតាមបរទេស (ចាស!ចាស! ឬ អូខេ!អូខេ!) ។

៩-ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ រាល់ការផ្សព្វផ្សាយពាណិជ្ជកម្ម មិនត្រូវភូតកុហកបំផ្លើសលើសការពិត ពីគុណភាព និងបរិមាណ ដែលជាហេតុបណ្តាលអោយគ្រោះថ្នាក់ដល់សុខភាព និងអាយុជីវិត ។ ដោយឡែក ស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវសរសេរអក្សរជាតិ អោយធំជាងហើយនៅលើអក្សរបរទេស ទាំងនៅលើផ្ទាំងអាហ្វីសផ្សាយពាណិជ្ជកម្ម និងនៅលើឆាកសំដែងក្តី ។រយៈពេល១០នាទីក្នុងកម្មវិធីអាចផ្សាយពាណិជ្ជកម្មបានម្តង ។

១០-ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ មិនអនុញ្ញាតអោយផ្សាយពាណិជ្ជកម្ម ដែលពុំមានការទទួលខុសត្រូវពីភាគីម្ចាស់ដើម ឬរបស់ក្លែងក្លាយ និងបង្ខូចកេរ្តិ៍ឈ្មោះបង្អាប់អ្នកដទៃ ហើយមានលក្ខណៈលើកទឹកចិត្តអោយកុមារជក់បារី និងផឹកគ្រឿងស្រវឹង ។

១១- ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ មិនអនុញ្ញាតអោយផ្សាយពាណិជ្ជកម្ម ឱសថឬការព្យាបាលជម្ងឺ ដែលមានលក្ខណៈឃោសនាបំផ្លើសអូសទាញ ឬធ្វើអោយមានការភ័យខ្លាច និងអស់សង្ឃឹម ។ ការផ្សាយពាណិជ្ជកម្ម ឱសថឬការព្យាបាលជម្ងឺ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល និងក្រសួងពត៌មាន ។

១២- ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ ត្រូវអាន និងបញ្ចាំងពាក្យស្លោក "ពិសារបារីនាំអោយគ្រោះថ្នាក់ ដល់សុខភាព" ។ពិសេសទូរទស្សន៍ ត្រូវបញ្ចាំងពាក្យស្លោកនេះអោយបានយូរ ។

១៣- ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ទាំងអស់ ត្រូវយកចិត្តទុកដាក់បង្កើតថែមទៀត នូវកម្មវិធីអប់រំ បណ្តុះបណ្តាល នាទីស្វែងយល់ពីបរិស្ថាន បេតិកភ័ណ្ឌជាតិ កម្មវិធីសិល្បៈ វប្បធម៌ សុខាភិបាល ចរាចរ និងនាទីកំសាន្តផ្សេងៗ.......... ។ល ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

លឺ ឡាយស្រេង

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-សាលាក្រុងភ្នំពេញ

"<u>ដើម្បីជ្រាបជាពត៌មាន</u>"

-គ្រប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍និងទូទស្សន៍ខ្សែកាប

-នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយនិងសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌មាន

- មន្ទីរពត៌មានរាជធានីភ្នំពេញ

"<u>ដើម្បីអនុវត្ត</u>"

-តម្កល់ទុកជាឯកសារ